# ចងចាំ ពាក្យ និងអក្សរ បង្កើនប្រាជ្ញា




អក្សរនិងពាក្យគឺមានជុំវិញខ្លួនយើងទាំងអស់គ្នា! ចង្អុលទៅពួកវា ហើយធ្វើឲ្យពេលវេលាប្រចាំថ្ងៃទៅជាពេលបង្កើនប្រាជ្ញាផងដែរ!

## បិទបង្ហាញគំនូសតាងអក្ខរក្រម។

អ្នកនឹងធ្វើឲ្យអក្សរស្រួលចងចាំ ហើយអាចប្រៀបធៀបបាននៅពេលអ្នកនិយាយអំពីអក្សរនិងសម្លេង។




## បង្កើនពាក្យនៃការមើលឃើញជាមួយការយល់ដឹង

សរសេរបិទពាក្យ "តុ" ឬ "កៅអី" ឬ "ទ្វារ" ដើម្បីឲ្យពាក្យទាំងនោះត្រូវបានតភ្ជាប់ជាមួយនឹងវត្ថុដែលធ្លាប់ស្គាល់។




## ធ្វើដំណើរទៅ ស្វែងរកអក្ខរក្រម

អក្សរនិងពាក្យគឺមានជុំវិញខ្លួនយើងទាំងអស់គ្នា។ រកពួកវាជាមួយគ្នានៅពេលអ្នកទៅដើរទិញឥវ៉ាន់, ដើរលេង, ទៅញ៉ាំអាហារនៅហាង, ឬជិះរថយន្តតូច, រថយន្តក្រុង, ឬរថភ្លើង។

**A** រកបីអក្សរ

**B** ចូររាប់តើអ្នកអាចរកអក្សរនោះឃើញប៉ុន្មានដង។

**C** តើអក្សរមួយណាអ្នករកឃើញច្រើនជាងគេ?

**D** តើអក្សរមួយណាអ្នករកឃើញតិចជាងគេ?






ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ /BrainBuildingInProgress

BrainBuildingInProgress.org

Department of Early Education and Care

United Way

BRAIN BUILDING IN PROGRESS



# ការសរសេរ

## ដើម្បីបង្កើនប្រាជ្ញា

នៅពេលណាកូនក្មេងឃើញមនុស្សចាស់សរសេរ,ពួកគេរៀនថានោះជាជំនាញដ៏សំខាន់មួយ។ ទាំងនេះជារបៀបធ្វើឲ្យពេលវេលាប្រចាំថ្ងៃទៅជាពេលបង្កើនប្រាជ្ញាផងដែរ!



### ធ្វើជាគំរូ

- នៅពេលផ្ញើអ៊ីមែល ឬបំពេញបែបបទ,និយាយពន្យល់អំពីអ្វីអ្នកកំពុងធ្វើ។
- សរសេរបញ្ជីរួមគ្នា,បំពេញប្រតិទិន ឬសរសេរ លិខិតមួយទៅមិត្តម្នាក់។

### លើកទឹកចិត្តដល់ការសរសេរ។

- មានក្រដាស,ខ្មៅដៃ, ដីសពណ៌សម្រាប់គូរ ឬបិចគូរ ស្រួលរកនឹងនៅជិតដៃឈោង។
- យកទៅជាមួយនៅពេលទៅណាមកណា។



### ធ្វើជាសៀវភៅមួយដោយខ្លួនឯង

- វាអាចជារឿងនិទានដែលពួកគេនឹកឃើញដោយ រៀបរាប់ជាគំនូរ។
- ឬ, និយាយរឿងអំពីគ្រួសារ, មិត្តភក្តិ, សត្វចិញ្ចឹម, ឬអាចប្រើរូបថតក៏បាន។ ទាំងអស់គ្នា, អ្នកនឹងមានបន្សល់ទុកជាអនុស្សាវរីយ៍ក្នុងខណៈការលើកទឹកចិត្តនៃការយល់ដឹងពីសៀវ ភៅ, ផ្នែកខ្លះនៃសៀវភៅ, និងដំណើរការនៃការរៀន អាន។




### មានភាពសប្បាយរីករាយជាមួយគ្នា!

1 បំពេញក្រដាសនំខុកឃីជាមួយ ត្រឹមកោរពុកមាត់ ឬ រាយខ្សាច់ ហើយគូសជានជាអក្សរ។

2 សរសេរពាក្យទាំងអស់គ្នាលើកញ្ចក់ ឬបង្អួចដើលចុះ អ័ព្ទ។

3 សូមសន្ទនាអំពីរបៀបដែលប្រភេទនៃការសរសេរនេះមានអារម្មណ៍ខុសផ្លែកពីការសរសេរដោយប្រើខ្មៅដៃឬ ដីគូសពណ៌មួយ។



ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ
/BrainBuildingInProgress

BrainBuildingInProgress.org

Department of Early Education and Care

United Way

BRAIN BUILDING IN PROGRESS

# បង្កើនកម្លាំងដៃក្មេងៗ

## ដើម្បីបង្កើនប្រាជ្ញា

ដៃក្មេងៗត្រូវការមានកម្លាំង រឹងមាំដើម្បីកាន់ឧបករណ៍សរសេរ និងផ្គុំរៀបចំអក្សរឲ្យច្បាស់។ នេះគឺជារបៀបបង្កើនកម្លាំងនោះខណៈ ធ្វើឲ្យពេលវេលាប្រចាំថ្ងៃក្លាយទៅជាពេលបង្កើនប្រាជ្ញាផងដែរ!



### បង្កើនសាច់ដុំសរសេរជាមួយការ “ហាត់ប្រាណ”

- ច្របាច់បាល់ដីខ្សាច់បារាំង
- រាប់តើអាចធ្វើ “ច្រំដែលៗ”បានប៉ុន្មានដង

### ស្គរសម្លេងក្រើប! ស្គរសម្លេងបង្រួមឲ្យតូច! ស្គរសម្លេងផប់!

ធ្វើឲ្យមានសម្លេងនៅពេលអ្នកបង្កើនសាច់ដុំ។

- ដៃក្មេងតូចចូលចិត្តកាច់សណ្តែកគួរ ឬសំបកភី
- ហែក ហើយបង្រួមក្រដាសគ្រប់ប្រភេទ។
- បំបែកថង់ផ្លាស្ទីករុំរបស់របរ។
- និយាយអំពីសម្លេងផ្សេងៗដែលអ្នកបានធ្វើ។ និងថាតើ ដៃរបស់អ្នកអាចធ្វើឲ្យឮសម្លេងប៉ុណ្ណា



### មានភាពរីករាយដែលផ្លែកៗ

កាត់ក្រដាស, លេងដីបារាំង, ស្មៅ,ក្រណាត់ ឬរបស់ផ្សេងៗ (ជាមួយកូនកន្ត្រៃសន្តិសុខសម្រាប់ក្មេងៗ) បង្កើនកម្លាំងសាច់ដុំដៃ និងភាពរហ័សផ្នែកដៃនិង ភ្នែក។

- ចាប់ផ្តើមដោយរៀនបើក និងបិទកន្ត្រៃ
- សួរថាតើមានអារម្មណ៍ដូចម្តេចពេលកាត់ក្រដាស
- តើមានអារម្មណ៍ផ្លែកពីការកាត់ដីបារាំងឬស្មៅទេ?



## តាមស្នាមកន្ត្រៃ!

គូរឲ្យមានស្នាមខ្សែត្រង់, ខ្សែកង់ៗ ឬខ្សែកាច់កុង ហើយយកកន្ត្រៃកាត់តាមគំនូសទាំងនោះ។ បង្កើនឲ្យមានការលំបាកផ្នែកផ្លូវ ឬគំរូ ឬក្រដាសក្រាស់ធ្វើជាថង់ដាក់បន្លែ ឬប្រអប់សីរៀល។






ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ
/BrainBuildingInProgress

BrainBuildingInProgress.org

Department of Early Education and Care

United Way

BRAIN BUILDING IN PROGRESS

# រៀនរាប់ ដើម្បីបង្កើនប្រាជ្ញា



ក្មេងតូចៗកំពុងរៀនជំនាញសំខាន់ៗផ្នែកគណិតវិទ្យាដែលកំពុងចំណូលចិត្តគេប្រើច្រើន។ ជួយពួកគេក្នុងការកសាងការយល់ដឹងនៃតួរលេខដែលមានក្នុងពិភពនៅជុំវិញពួកគេ។ នេះគឺជារបៀបធ្វើឲ្យពេលវេលាប្រចាំថ្ងៃក្លាយទៅជាពេលបង្កើនប្រាជ្ញាផងដែរ!




## បង្ហាញថាតួរលេខគឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃ។

- រាប់, សរសេរលេខ និងដោះស្រាយបញ្ហា នៅពេលអ្នកកំពុងធ្វើអ្វីមួយ ឬចេញដំណើរធ្វើកិច្ចការ
- ចំណាំលេខនៅពេលអ្នកឃើញវា – ក្នុងអស័យដ្ឋាន,តម្លៃរបស់ក្នុងហាង, នៅលើក្តាសរសេរ,ឬទូរស័ព្ទ។
- សួរសំនួរទាំងឡាយដូចជា, "ប្រសិបើខ្ញុំមានប៉មពីរ, តើខ្ញុំមានច្រើនជាងអ្នកដែលមានប្រាំមួយឬទេ?"



## រាប់ឲ្យឮទាំងអស់គ្នា។

- បិទតារាងលេខ, ដូចកាលអ្នកបានបិទអក្ខរក្រម
- ចង្អុលទៅវា នៅពេលណានិយាយអំពីលេខម្តងៗ ធ្វើតាមបន្ទាត់លេខរៀង, អានវាម្តងមួយៗ

BRAIN BUILDING IN PROGRESS



## បង្កើនប្រាជ្ញាតាមរយៈតួរលេខ!

ក្នុងរថយន្ត៖ រាប់ពីចំនួនប៉ុន្មានដងដែលអ្នកមើលឃើញសញ្ញា ឬវត្ថុផ្សេងៗ។ នៅពេលណាអ្នកបើកចូលរូងផ្លូវម្តងៗ ចូររាប់តើដល់ លេខប៉ុន្មានទើបចេញផុត។ អានលេខនៅលើសញ្ញាទាំងឡាយខ្លាំងៗ។

នៅហាងលក់គ្រឿងទេស: រាប់ចំនួនផ្លែឈើដែលអ្នកកំពុងទិញហើយដាក់ពួកវាក្នុងថង់។ ឲ្យ "អ្នកជំនួយការ" របស់អ្នកយករបស់ចេញពីរទេះ ហើយរាប់តើអ្នកកំពុងទិញរបស់ចំនួនប៉ុន្មាន។

ឯកន្លែងក្មេងលេង៖ រាប់នៅពេលអ្នកប្រានតួងម្តងៗ គូលេខផ្សេងៗលើដីខ្សាច់ក្នុងប្រអប់ដីខ្សាច់។ សួរសំនួរផ្សេងៗដូចជា, "តើមានកូនក្មេងប៉ុន្មាននាក់ ដែលកំពុងលេងលើក្តាររំអិល?"

ពេលដើរ៖ តើដើរពីទីនេះទៅទីនោះមានប៉ុន្មានជំហ៊ាន? រកមើលលេខផ្ទះ,ឬរាប់តើអ្នកមើលឃើញមានឡាន ឬដើមឈើប៉ុន្មាន។

ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ /BrainBuildingInProgress

BrainBuildingInProgress.org

eec Department of Early Education and Care

United Way

# និយាយអំពី ចិត្តារម្មណ៍

## ដើម្បីបង្កើនប្រាជ្ញា

ការសន្ទនាអាចជួយបង្កើនប្រាជ្ញារបស់កុមារ។ កុមារណាដែលអ្នកផ្តល់ជំនួយផ្នែកអារម្មណ៍ អាចជួយពួកគេបង្កើនជំនាញសំខាន់ៗផ្សេងទៀតនៃការទំនាក់ទំនងសង្គម។ កុមារណាដែលអាចដឹងហើយចេះបញ្ចេញអារម្មណ៍ របស់ពួកគេ នឹងមានការរៀបចំល្អដើម្បីចូលរៀននៅ មត្តេយ្យដ្ឋាន។ នេះគឺជារបៀបធ្វើឲ្យពេលវេលាប្រចាំថ្ងៃក្លាយទៅជាពេលបង្កើនប្រាជ្ញាផងដែរ!

## ការដោះស្រាយបញ្ហា

ជួយកុមារដែលមានចិត្តខឹង ឬធុញថប់ដោះស្រាយ បញ្ហា។ ប្រើមធ្យោបាយដូចជាដូរគ្នាម្តងម្នាក់,រករបស់ក្មេងលេង,ឬប្រើជម្រើសផ្សេងទៀត។ ប្តូរគ្នានាទីគ្នាដើម្បីរៀនជំនាញដោះស្រាយបញ្ហាផ្សេងៗ នេះអាចជួយពួកគេបង្កើនមិត្តភាព និងទំនាក់ទំនង ក្នុងសាលារៀន។

## និយាយអំពីអារម្មណ៍

ប្រើរូបភាពដូចមុខមាត់ទាំងឡាយខាងក្រោមដើម្បីជាសម្គាល់ ហើយយល់ដឹងអំពីអារម្មណ៍ទាំងឡាយ និងអារម្មណ៍របស់អ្នកដទៃ។ បិទរូបទាំងឡាយនៅលើកញ្ចក់ដើម្បីឲ្យកុមារអាច ឃើញអំពីទឹកមុខ,ឬប្រៀបធៀបទៅនឹងរូបភាពផ្សេងៗនៅក្នុងសៀវភៅ។




Reproduced from the Center on the Social Emotional Foundations of Early Learning
http://csefel.vanderbilt.edu/modules/2006/feelingchart.pdf



ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ /BrainBuildingInProgress

BrainBuildingInProgress.org

Department of Early Education and Care

United Way

# រៀនអាន

## ដើម្បីបង្កើនប្រាជ្ញា



ការសន្ទនាទៅវិញ-ទៅមកនឹងទំនាក់ទំនងគ្នាដែល កើតមានឡើងនៅពេលអ្នកអានជាមួយគ្នាបង្កើន ប្រាជ្ញារបស់កុមារ។ នេះគឺជារបៀបធ្វើឲ្យពេលវេលាប្រចាំថ្ងៃក្លាយទៅជាពេលបង្កើនប្រាជ្ញាផងដែរ!

### បើកសៀវភៅមើលត្រួសៗមុនពេលអានវាឱ្យខ្លាំងៗ។




- A មើលគម្របសៀវភៅខាងមុខ។
- B និយាយអំពីអ្វីដែលអ្នកបានគិតថានឹងកើតឡើងនៅក្នុងសៀវភៅនោះ។

### យកចិត្តទុកដាក់ទៅលើរូបភាពទាំងឡាយ។

កុមារតូចៗប្រើតម្រុយនៃរូបភាពលើសៀវភៅដើម្បី ជួយពួកគេយល់, គិត,ចងចាំហើយនិទានរឿងនោះ ជាគ្រឹះនៃការរៀនអាន។ ធ្វើជា "ដំណើរនៃរូបភាព" ហើយពិភាក្សាអំពីអ្វីដែលបានឃើញលើទំព័រនិមួយ។ មើលរូបភាពទាំងនោះ ហើយសួរពួកគេថាតើមានរឿងអ្វីដែលកំពុងកើតឡើង។

### បង្ហាញអំពីខ្លួនអ្នក!

ការរំភើបចិត្តដោយបញ្ចេញតាមសម្លេងរបស់អ្នកគឺជាការចូលរួមមួយផ្នែកនៃការដកពិសោធន៍មួយ។

- A សន្ទនាអំពីរឿងអ្វីដែលកំពុងកើតមានឡើងជាបន្តបន្ទាប់
- B សួរ ហើយឆ្លើយអំពីអ្វីដែលកំពុងកើតមានឡើងក្នុងសៀវភៅ។
- C ចង្អុលទៅអ្វីដែលមាននៅលើទំព័រ ហើយលើកទឹកចិត្តឲ្យពួកគេសង្កេតតាមដាន
- D តភ្ជាប់ពីអ្វីដែលកើតមានក្នុងសៀវភៅទៅនឹងការដកពិសោធន៍របស់កូនអ្នក។

### មានការសប្បាយរីករាយជាមួយគ្នា!

- ★ ជ្រើសរើសសៀវភៅដែលត្រូវនឹងចំណូលចិត្ត – ទោះបីវាជារឿងសត្វដាយណាសរ,ឡានធំ,កូនឆ្កែតូចៗ ឬព្រះនាង,ពួកគេនឹងចូលចិត្តជាមិនខាន។
- ★ បន្ធូរអារម្មណ៍! ប្រសិនបើក្មេងនៅមិនស្ងៀម ឬមួម៉ៅ, នេះមិនមានន័យថាពួកគេមិនស្តាប់អ្នកទេ។ ចំពោះកុមារខ្លះៗ,ការរើបម្រះខ្លួនប្រាណរបស់គេគឺអាចជួយឲ្យពួកគេគិត។ វាមិនអីទេប្រសិនបើកុមារមិនអង្គុយស្តាប់រឿងទាំង ស្រុងនោះ។
- ★ ត្រូវប្រុងប្រៀបអានសៀវភៅដដែលនោះម្តងហើយម្តងទៀត។ ការចងចាំសាច់រឿងផ្សេងៗជួនកាលអាចជាជំហ៊ាន ដំបូងក្នុងការខ្លាយទៅជាអ្នកអានដ៏ល្អមួយ។




ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ /BrainBuildingInProgress

សិក្សាបន្ថែម និងស្វែងយល់អំពីកម្មវិធី,ព្រឹត្តិការណ៍,និងធនធានផ្សេងៗតាមរយៈ
**BrainBuildingInProgress.org**

Department of Early Education and Care

United Way

BRAIN BUILDING IN PROGRESS

# ការនិយាយ

## អំពីសៀវភៅផ្សេងៗ

នេះគឺជារបៀបស្វែងរកសៀវភៅដើម្បីឲ្យការរៀនអានក្លាយទៅពេលវេលាបង្កើនប្រាជ្ញាផងដែរ!





## ធ្វើការរៀនអានជាកម្មវិធីទៅវិញ-ទៅមក។

- A ទាក់ទង ហើយតភ្ជាប់។កុំចេះតែអានឲ្យកូនស្តាប់,ត្រូវអានជាមួយនឹងកូនស្រី/ប្រុស។ សួរជាសំនួរ ហើយអនុញ្ញាតឲ្យកូនរបស់អ្នកបើកទំព័រមួយទៀត។
- B ពិគ្រោះគ្នាអាចបង្កើនភាសា និងការអានអក្សរ,ព្រមទាំងបន្តការបង្កើនប្រាជ្ញា។

## តភ្ជាប់សៀវភៅជាមួយជីវិតពិតៗ និងពិភពខាងក្រៅ។

ការរំភើបចិត្តដោយបញ្ចេញតាមសម្លេងរបស់អ្នកគឺជាការចូលរួមមួយផ្នែកនៃការដកពិសោធន៍មួយ។

- A តើតួរទាំងនោះដូចមនុស្សពួកគេធ្លាប់ស្គាល់ឬទេ?
- B តើរឿងកើតឡើងក្នុងសៀវភៅមានកើតឡើងចំពោះរូបពួកគេដែរឬទេ?
- C ចែករំលែកនូវអ្វីដែលអ្នកបានដឹងអំពីកន្លែងដែលរឿងកើតឡើង ឬអ្វីមួយនៅក្នុងសៀវភៅដែល បង្កើនការយកចិត្តទុកដាក់។

## ណែនាំពីគោលគំនិតថ្មីៗ

- A ពន្យល់ពីមូលហេតុដែលសៀវភៅអានពីមុខទៅក្រោយ ឬពីឆ្វេងទៅស្តាំ។
- B ចង្អុលប្រាប់ពីប្រយោគនិមួយៗចាប់ផ្តើមជាមួយអក្សរ ធំ ហើយបញ្ចប់ជាមួយសញ្ញាវណ្ណយុត្ត។
- C ស្វែងរកសញ្ញាពិន្ទុឧទានផ្សេងៗ។ ពួកគេមានន័យថានៅក្នុងរឿងនោះមានអ្វីមួយរំភើបបានកើតឡើង!

BRAIN BUILDING IN PROGRESS

## សំនួរទាំងឡាយដែលត្រូវសួរ៖

- ★ តើរូបភាពនេះអាចប្រាប់ថានឹងមានអ្វីអាចនឹងកើតឡើងខាងមុខក្នុងរឿងនេះឬទេ?
- ★ តើវាដែលមានកើតឡើងចំពោះអ្នកឬទេ?
- ★ តើមានអ្វីកើតឡើងបន្តទៀត?
- ★ តើគាត់បានទៅណា? ហេតុអ្វីបានជានាងធ្វើដូច្នេះ?
- ★ តើអ្នកគិតថានាងនឹងមានចិត្តយ៉ាងដូចម្តេច?
- ★ តើអ្នកចូលចិត្តផ្នែកមួយណាជាងគេ? ហេតុអ្វីបានជាអ្នកចូលចិត្ត?
- ★ ខ្ញុំឆ្ងល់ថា ប្រសិនបើ...?
- ★ នោះជាសំនួរល្អណាស់។ តើអ្នកមានទៀតឬទេ?



ប្រាប់យើងខ្ញុំពីរបៀបដែលអ្នកបានប្រើគំនិតទាំងនេះ ឬចែករំលែកគំនិតផ្ទាល់ខ្លួនតាមរយៈ /BrainBuildingInProgress

BrainBuildingInProgress.org

eec Department of Early Education and Care

United Way